ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
ក្រុមប្រឹក្សាភិបាលមូលនិធិនៃការកសាងសមត្ថភាព
និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍
និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

# សេចក្តីជូនព័ត៌មាន

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ប្រកាសបើកនូវកម្មវិធីមួយមានឈ្មោះថា "ស្ត្រីកម្ពុជាក្នុងវិស័យបច្ចេកវិទ្យា[១]"។ កម្មវិធីនេះ មានគោលបំណងលើកទឹកចិត្តស្ត្រីឱ្យចូលរួមកាន់តែច្រើនផុសផុល នៅក្នុងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានដើម្បីចូលរួមចំណែកក្នុងការពាំនាំ និងកែប្រែកម្ពុជាឱ្យក្លាយទៅជាប្រទេសមួយដែលមានសក្តានុពល និងរីកចម្រើននៅក្នុងយុគសម័យឌីជីថលនេះ។

កម្មវិធីនេះផ្តោតលើប្រធានបទ "**ការផ្តល់សិទ្ធិអំណាចដល់ស្ត្រីតាមរយៈបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន**" នឹងប្រកាសរកបេក្ខភាពជាស្ត្រី ចាប់ពីថ្ងៃនេះ រហូតដល់ថ្ងៃទី ០១ ខែមីនា ឆ្នាំ ២០១៨។ បន្ទាប់មកក្រសួងនឹងធ្វើការជ្រើសរើស ហើយវាយតម្លៃរកស្ត្រីឆ្នើមដែលមានគុណសម្បត្តិគ្រប់គ្រាន់។ ជ័យលាភី ០៣ (បី) រូប នឹងត្រូវផ្តល់កិត្តិយសទទួលពានរង្វាន់ នៅថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៨ ខាងមុខ។

*ពាក់ព័ន្ធនឹងការរៀបចំកម្មវិធីនេះឡើង* ***ឯកឧត្តម កាន ច័ន្ទមេត្តា*** *រដ្ឋលេខាធិការនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានមានប្រសាសន៍ថា: " កន្លងមកយើងមើលឃើញថា ស្ត្រីកម្ពុជាមានចំនួនតិចតួចណាស់ដែលបានចាប់យកជំនាញ និងធ្វើការក្នុងវិស័យនេះ ទោះជាពួកគាត់មានសមត្ថភាព និងការច្នៃប្រឌិតប្លែកៗមិនចាញ់បុរសក៏ដោយ។ ដើម្បីជំរុញការចូលរួមបន្ថែមទៀត យើងចាំបាច់ត្រូវបង្កើតកម្មវិធីលើកទឹកចិត្តនានា។ ជាលទ្ធផល ពានរង្វាន់ស្ត្រីឆ្នើមក្នុងវិស័យបច្ចេកវិទ្យានេះ នឹងជួយបំផុសទឹកចិត្តឱ្យស្ត្រីដទៃទៀតចាប់អារម្មណ៍ និងចូលរួមជាបន្តបន្ទាប់"។*

កម្មវិធីនេះមានពានរង្វាន់ផ្នែកបច្ចេកវិទ្យាចំនួន ០៣ (បី) ប្រភេទ គឺ **សហគ្រិនឆ្នើមស្ត្រីក្នុងបច្ចេកវិទ្យា** (Cambodian Woman ICT Entrepreneur Award) **វិស្វករស្ត្រីជោគជ័យក្នុងជំនាញ ប.គ.ព** (Cambodian Woman ICT Engineer Award) និងចុងក្រោយគឺ **ស្ត្រីដែលបានចូលរួមជំរុញនូវការប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ការអភិវឌ្ឍសង្គមឬសហគមន៍** (Cambodian Woman ICT For Community Award)។

សូមបញ្ជាក់ថា ស្ត្រីឆ្នើមនៅកម្ពុជាទាំង០៣ (បី) ប្រភេទដែលត្រូវបានជ្រើសរើសត្រូវតែជាក្រុមស្ត្រីកម្ពុជាដែលមានសក្តានុពលក្នុងផ្នែកបច្ចេកវិទ្យា មានភាពជាអ្នកដឹកនាំខ្ពស់ ព្រមទាំងបានប្រើប្រាស់នូវជំនាញរបស់ខ្លួនដើម្បីបម្រើការក្នុងស្ថាប័នរបស់ខ្លួន ក៏ដូចជានៅក្នុងសហគមន៍របស់ខ្លួនរហូតមកដល់ពេលបច្ចុប្បន្ននេះ។ ក្រៅពីនេះ ពួកគាត់ក៏ត្រូវតែជាស្ត្រីកម្ពុជាដែលបានលះបង់នូវពេលវេលា និងកម្លាំងកាយចិត្តរបស់ខ្លួនដោយស្ម័គ្រចិត្ត ដើម្បីចូលរួមយ៉ាងសកម្មនៅក្នុងការចូលរួមស្វែងរកដំណោះស្រាយផ្នែកណាមួយក្នុងវិស័យបច្ចេកវិទ្យា សម្រាប់យកមកបម្រើផលប្រយោជន៍ក្នុងសង្គមកម្ពុជាជារួម។

[១] បច្ចេកវិទ្យា សំដៅដល់ បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (ប.គ.ព)។

អគារលេខ ១៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ.
ទូរស័ព្ទ (៨៥៥) ២៣-៧២៤៨១០/៤២៦៥១០
ទូរសារ (៨៥៥) ២៣-៧២៤០៦៩

សាធារណៈជនអាចចូលរួមក្នុងកម្មវិធីនេះបាន ដោយស្នើបេក្ខភាព ស្ត្រីដែលលោកអ្នកគិតថាជាស្ត្រីឆ្នើមឬស្ត្រីគំរូក្នុងវិស័យនេះ។ ការស្នើបេក្ខភាពអាចធ្វើឡើងតាមប្រព័ន្ធអនឡាញ ដោយគ្រាន់តែចូលទៅក្នុងតំណភ្ជាប់

http://cbrd.gov.kh/nominations ឬអាចទំនាក់ទំនងតាមសារអេឡិចត្រូនិក info@cbrd.gov.kh ឬ ទូរស័ព្ទលេខៈ

**023 723 121 ឬ 086 47 87 72 ។**

ថ្ងៃពុធ ៧កើត ខែផល្គុន នព្វសក ព.ស. ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨